# ការបន្តការពិភាក្សាពីឯកសារភ័ស្តុតាងក្នុងសំណុំរឿង ០០២ : សក្ខីកម្មថ្ងៃចុងក្រោយរបស់លោក ឆាំង យុ

ដោយ រ៉េនឌល ឌីហ្សាលកូ

ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១២

ប្រែសម្រួលដោយ ហ៊ុយ សម្ផស្ស

*ឯកសាររបស់មជ្ឈមណ្ឌលកម្ពុជា គ្រាន់តែជា“ទឹកមួយតំណក់ក្នុងមហាសមុទ្រចុំណ្ណោះ” នៅក្នុងចំណោមឯកសារដែលខ្មែរក្រហមបានបង្កើតនោះ ។*

*--លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា*

នៅថ្ងៃចន្ទ័ទី៦ ខែកុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះវិសមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បន្ត សវនការស្តាប់សក្ខីកម្មលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងវិធីសាស្រ្ត និងដំណើរការប្រមូលឯកសារនានា ។[១] ថ្ងៃនេះជាថ្ងៃចុងក្រោយក្នុងការផ្តល់សក្ខីកម្មរបស់លោក ឆាំង យុ លើការអនុវត្ត និងដំណើរការប្រមូលឯកសារ ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មអស់រយៈពេលពីរថ្ងៃពេញទាក់ទងទៅនឹងគោលការណ៍នានារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ រាល់ពេលមានអវត្តមានក្នុងការចោទសួររបស់លោក លោកហាក់ដូចជាធ្វើឲ្យអ្នកចូលរួមមានការប្លែកសប្បាយ ដោយការស្លៀកពាក់ផ្សេងៗ ។ ប្រហែលជាក្នុងចំណុចនេះ លោក ឆាំង យុ បានចូលមកសវនការនៅថ្ងៃបញ្ចប់នៃការផ្តល់សក្ខីកម្មរបស់លោកជាមួយសម្លៀកបំពាក់អាវធំ និងក្រមាខ្មែរពណ៌ក្រហម ដែលរុំជុំវិញករបស់លោក ។ ក្រមាពណ៌ក្រហមនេះគឺជាស្តង់ដាសម្លៀកបំពាក់របស់ខ្មែរក្រហម ដែលពាក់ជាមួយសម្លៀកបំពាក់ពណ៌ខ្មៅសុទ្ធ ។

មុនពេលចាប់ផ្តើមសំណួរសម្រាប់ថ្ងៃនេះ ក្រុមមេធាវីការពារក្តី អៀង សារី បានជម្រាបអង្គជំនុំជម្រះថាមុនពេលអង្គជំនុំជម្រះសម្រេចទទួលយកនូវ“ការសន្និដ្ឋានប្រឆាំង” ក្នុងបំណងទទួលយកនូវភស្តុតាងយោងទៅតាមការបញ្ចប់ការស៊ើបអង្កេតដោយសហចៅក្រមស៊ើបអង្កេត វាមិនគួរដាក់បញ្ចូល

---

[១] មជ្ឈមណ្ឌលឯកសារកម្ពុជា ស្រាវជ្រាវ ពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ ពី (១៩៧៥ -១៩៧៩) និងបានផ្តល់ឯកសារភស្តុតាងជាច្រើនទៅឲ្យ អ.វ.ត.ក ។

សំណួរនានារបស់លោក ឆាំង យុ ទេ។ ក្រុមមេធាវី នួន ជា ក្រោយមកស្នើថា ពេលវេលាខ្លះ និងបានបែងចែកឲ្យទៅក្រុមមេធាវីការពារក្តី អៀង សារី ក្នុងពេលសាកសួររបស់ក្រុមនេះមកឲ្យក្រុមខ្លួនវិញ។ ឆ្លើយតបទៅនឹងសំណើនេះ អង្គជំនុំជម្រះបានថ្លែងថា នឹងពិចារណាទៅនឹងបញ្ហាពេលវេលាមុនពេលសម្រេច និងណែនាំឲ្យលោក ហ្សាស្តេ ប៉ាវ មេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា ចាប់ផ្តើមធ្វើការសួរសំណួរ។

## ហ្សាស្តេ ប៉ាវ មេធាវីការពារក្តីអន្តរជាតិរបស់ នួន ជា ចាប់ផ្តើមសួរទៅសាក្សី ឆាំង យុ ក្នុងនាមក្រុម។ (ក្រោមរូបថត)

លោក ប៉ាវ ចាប់ផ្តើមសំណួរដោយសួរ លោក ឆាំង យុ ពីវិធីរកឯកសារដែលមាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលប្រើសម្រាប់បញ្ចូលទិន្នន័យពីប្រភពនៃឯកសារនានា។ លោក ឆាំង យុ បានបញ្ជាក់ថា របៀបប្រើនេះគឺប្រើដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងបញ្ជាក់ថាទម្រង់នេះគឺប្រើសម្រាប់កត់ត្រាព័ត៌មានបឋមពីប្រភពឯកសារដែលឯកសារនេះទទួលបាន និងកត់ត្រាព័ត៌មានដែលបានមកពីប្រភពឯកសារដើមដែលមាន និងទីតាំងដែលឯកសារនោះរកត្រូវរកឃើញ។ ឆ្លើយតបនឹងសំណួរបន្ថែមទៀត លោក ឆាំង យុ បញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រមូលព័ត៌មាននានាទាក់ទងទៅនឹងរាល់ប្រភពឯកសារដែលចូលមកមជ្ឈមណ្ឌលនេះ។ លោកក៏បានបន្ថែមទៀតថារាល់ការបញ្ចូលទិន្នន័យគឺវាមានលក្ខណៈបច្ចេកទេសបន្តិច ហើយលោក វ៉ាន់ថាន់ ពៅដារ៉ា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកទទួលមើលការខុសត្រូវការងារបញ្ចូលឯកសារនេះ។

លោក ប៉ាវ បានសួរថាតើវាអាចទៅរួចទេក្នុងការដកយកព័ត៌មានពីអ្នកកាន់កាប់ឯកសារពីមុន និងបច្ចុប្បន្នដែលរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទិន្នន័យនៃមជ្ឈមណ្ឌលនេះ? លោក ឆាំង យុ ឆ្លើយតបថាលោកជឿថា វាអាចធ្វើទៅបានប៉ុន្តែមិនមែនរាល់អ្នកកាន់កាប់ឯកសារទាំងអស់ចង់បង្ហាញអត្តសញ្ញាណរបស់ពួកគេទេ។ បន្ទាប់មកលោក ប៉ាវ សួរថា តើទិន្នន័យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថាតើរាល់ឯកសារកាន់ដោយមជ្ឈមណ្ឌលនេះ គឺជាឯកសារដើម ជាឯកសារដែលបង្កើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឬគ្រាន់តែជាឯកសារចម្លងទេនោះ? បន្ទាប់ពីមានការយល់ច្រឡំកើតឡើងទាក់ទងនឹងសំណួរដែលបានសួរ លោក ឆាំង យុ ឆ្លើយតបថា មជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាបានកត់ត្រា និងរក្សាទុកព័ត៌មានទាក់ទងនឹងរាល់ប្រភពឯកសារនីមួយៗមែន។ លោក ប៉ាវ សួរទៀតថាតើមជ្ឈមណ្ឌលនេះអាចផ្តល់រាល់ព័ត៌មាននេះបានដែរឬទេ? លោក ឆាំង យុ ឆ្លើយតបថា មជ្ឈមណ្ឌលឯកសារកម្ពុជា អាចផ្តល់ជូនបានប្រសិនបើមានការចាំបាច់។

ប្រធានបទបន្ទាប់ គឺលើកឡើងពីពិធីការនានាដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាទាក់ទងនឹងការធ្វើកោសល្យវិច្ឆ័យឯកសារផ្សេងៗ ។ លោក ឆាំង យុ ឆ្លើយតបថា លោកបានពិភាក្សាពីរឿងធ្វើពិនិត្យលើឯកសារនានានេះ ។ បន្ទាប់មក លោកផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជា ពីមុនមកបានគិតគូររៀបចំបង្កើតនីតិវិធីផ្សេងៗក្នុងការសហការជាមួយអ.វ.ត.ក ដែលអាចនឹងធ្វើកោសល្យវិច្ឆ័យលើកឯកសារផ្សេងៗដែលចាត់ទុកថាចាំបាច់ ហើយលោកបានឲ្យដឹងថាប្រហែលជាមន្ត្រីតុលាការ «មិនចាប់អារម្មណ៍ពីបញ្ហានេះទេ» ពីព្រោះគ្មាននីតិវិធីអ្វីទាំងអស់បានបង្កើតឡើងក្រោយមកទៀត ។ លោក ប៉ាវ បានសួរថាតើអ្នកជំនាញពីខាងក្រៅអាចត្រូវអនុញ្ញាតឲ្យចូលទៅមើលឯកសារដើម ដើម្បីធ្វើតេសលើឯកសារទាំងនោះឬទេ? បន្ទាប់ពីមានសំណួរជាច្រើនទាក់ទងនឹងបញ្ហានេះ លោក ឆាំង យុ ចុងក្រោយពន្យល់ថា មានអ្នកជំនាញម្នាក់បានមកមជ្ឈមណ្ឌលឯកសារកម្ពុជា និងទាមទារធ្វើកោសល្យវិច្ឆ័យលើឯកសារនានា ។ លោកបានឲ្យដឹងទៀតថា អ្នកជំនាញនេះមិនបានធ្វើការតាមដានពីការស្នើសុំជាដំបូងដើម្បីធ្វើតេសលើឯកសារខ្លះ និងគ្មានអ្នកជំនាញណាមួយបានធ្វើកិច្ចការនេះទេ ។ សម្រាប់ការធ្វើតេសតាមរូបរាង លោក ឆាំង យុ ផ្តល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជា ពឹងផ្អែកទៅលើអ្នកជំនាញ និងបុគ្គលិកមកពីបណ្ណសារដ្ឋានជាតិ ដែលមានបទពិសោធន៍ខាងឯកសារជាង៣០ឆ្នាំមក ហើយដើម្បីកំណត់ពីភាពត្រឹមត្រូវពិតប្រាកដរបស់ឯកសារដែលទទួលបាន ។ លោក ប៉ាវ បានសួរថា តើលោក ឆាំង យុ បានដឹងពីឯកសារដើមនានា «សៀវភៅខ្មៅ» ដែលបង្កើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ឆាំង យុ បានឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជា មានមួយច្បាប់ដែលបកប្រែជាភាសាអង់គ្លេសដែលបានបោះពុម្ពនៅទីក្រុងញូយ៉ក នៅឆ្នាំ១៩៧៨ និងច្បាប់ដើមមួយនៃសៀវភៅនេះដែលសរសេរជាភាសាបារាំង ។ លោក ឆាំង យុ បានបញ្ជាក់ថាមជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាមានច្បាប់ដើមជាភាសាបារាំង និងថា គុណ្ណារ បឹកស្រ្តម និង ឡូរ៉ា សាំមើស៍ ក៏មានដើមដែរ ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មបន្ថែមទៀតថា លោកបានសួរអ្នកទាំងពីរនេះពីទីតាំងនៃឯកសារដើមនៃសៀវភៅខ្មៅកាលពីពេលថ្មីៗនេះ ដើម្បីកុំឲ្យមានការភ័ន្តច្រឡំមុនពេលធ្វើសក្ខីកម្មពីរឿងសៀវភៅខ្មៅនេះ ។ ប្រធានបទបន្ទាប់គឺលើកឡើងពីការបារម្ភរបស់លោក ប៉ាវ ទាក់ទងទៅនឹងទស្សនាវដ្តីក្នុងរបបខ្មែរក្រហមដែលបានមកពីប្រភពខាងអ៊ឺរ៉ុប ។ លោក ឆាំង យុ ឆ្លើយតបថា មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារទស្សនាវដ្តីក្នុងរបបខ្មែរក្រហមខ្លះពី គុណ្ណារ បឹកស្រ្តម និងខ្លះទៀតបានពីដើមបណ្តឹងរដ្ឋប្បវេណី និងខ្លះបានពីបុគ្គលមួយចំនួននៅប្រទេសបារាំង ។ លោកបានផ្តល់សក្ខីកម្មបន្ថែមទៀតថា អ្នកកាសែតពីសារព័ត៌មានញូយ៉កថៃមស៍ *“The New York Times”* ក៏បានផ្តល់ទស្សនាវដ្តីខ្លះ និងមានអ្នកខ្លះទៀតដែលលោកមិនចាំឈ្មោះអស់ ។ លោក ឆាំង យុ បន្ថែមថា «ខ្ញុំចូលចិត្តអានទស្សនាវដ្តី»

ដែលនេះជាហេតុដែលធ្វើឲ្យលោកប្រមូលឯកសារទាំងនេះ ។ បន្ទាប់មក លោក ប៉ាវ បែរទៅសួរពីកំណត់ត្រានានាដែលធ្វើឡើងដោយវៀតណាមលើឯកសារដើមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ឆាំង យុ ផ្តល់សក្ខីកម្មថា អ្នកស្រាវជ្រាវពីខ្មែរក្រហម លោក ប៊ែន ឃៀនិន បានបញ្ជាក់ពីការសរសេរកត់ត្រាថា ទាក់ទងទៅនឹង*សន្តិបាល* ។[២] បន្ទាប់មក លោក ប៉ាវ បានសួរថា តើវៀតណាមបានកាន់កាប់លើឯកសារក្នុងរបបខ្មែរក្រហមអស់រយៈពេលប៉ុន្មាន បន្ទាប់ពីការដួលរលំនៃរបបនេះ? លោក ឆាំង យុ ឆ្លើយតបថា លោក ក៏បានចង់ដឹងពីរឿងនេះដែរដោយសួរទៅក្រសួងមហាផ្ទៃកម្ពុជា តែលោកត្រូវបានឲ្យទៅសួរជំនាញការវៀតណាមម្នាក់ទាក់ទងនឹងរឿងនេះ ដែលលោកបានស្វែងរកចង់ជួប ប៉ុន្តែជំនាញការនោះបានស្លាប់បាត់ទៅហើយ នៅពេលដែលលោកធ្វើដំណើរទៅទីក្រុងហាណូយស្វែងរកគាត់នោះ ។ ក្រោយមកលោក ប៉ាវ សួរ លោក ឆាំង យុ ឲ្យធ្វើផ្តល់យោបល់លើថាតើមន្ត្រីវៀតណាមនោះ អាចនឹងបានផ្លាស់ប្តូរឯកសារមួយចំនួន ដើម្បីលាក់កំបាំងព័ត៌មានដែលអាចមានការប្រព្រឹត្តបទឧក្រិដ្ឋកម្មឬអំពើព្រៃផ្សៃផ្សេងទេ? សំណួរនេះធ្វើឲ្យមានការជំទាស់ភ្លាមៗពីខាងព្រះរាជអាជ្ញាដែលអះអាងថាសំណួរនេះចោទសួរមានបំណងចង់ឲ្យ លោក ឆាំង យុ ធ្វើការប៉ាន់ស្មាន ។ អង្គជំនុំជម្រះយល់ស្របនឹងការជំទាស់នេះ លោក ប៉ាវ ត្រូវបន្តសំណួរលើប្រធានបទបន្ទាប់ទៀត ។

ជា បន្ទាប់ទៀតលោក ប៉ាវ បានសួរ លោក ឆាំង យុ ប្រសិនលោកដឹងថា ហេតុអ្វីបានជាអាជ្ញាធរវៀតណាមបានប្រមូលឯកសារសម្រាប់តុលាការបដិវត្តន៍ប្រជាជនឆ្នាំ១៩៧៩ ។ លោក ឆាំង យុ ពន្យល់ថា លោកមិនមានវត្តមាននៅប្រទេសកម្ពុជាទេនៅពេលនោះ ដូចនេះមិនបានដឹងពីដំណើរការរបស់តុលាការនេះទេ ។ បន្ទាប់មក លោក ប៉ាវ សួរលោក ឆាំង យុ ប្រសិនបើ តុលាការនេះត្រូវគេយល់ថាជា«ការជំនុំជម្រះគួរខ្មាស់អៀន» អាចបំផ្លាញឯកសារ និងអាចលាក់កំបាំងឯកសារធ្វើឲ្យជនជាប់ចោទ ក្នុង អ.វ.ត.ក រួចពីបទចោទ ឬក៏ចោទប្រកាន់លើកងទ័ពវៀតណាម?

សំណួរនេះជំរុញឲ្យមានការជំទាស់ម្តងទៀតពីខាងព្រះរាជអាជ្ញា ដែលសារជាថ្មីម្តងទៀតសំអាងថា សំណួរនេះធ្វើឲ្យមានការប៉ាន់ស្មានដោយលោក ឆាំង យុ ទាក់ទងទៅនឹងប្រធានបទដែលនៅក្រៅពីការយល់ដឹងរបស់លោក ។ អង្គជំនុំជម្រះក៏បានយល់ស្របនឹងការជំទាស់ ហើយលោកប្រធានចៅក្រម និល ណុន ក៏បានណែនាំ លោក ប៉ាវ ដើម្បីកុំឲ្យសួរសំណួរដដែលមិនសមស្របទៅនឹងប្រធានបទ ។

បន្ទាប់មក លោក ប៉ាវ សួរពីការធ្វើដំណើរដែលគួរឲ្យសង្ស័យរបស់ លោកស្រី ហេឡិន ចារីស ទៅប្រទេសវៀតណាម ដើម្បីប្រមូលឯកសារពីរបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ឆាំង យុ

---

[២] ប៉ូលីសសម្ងាត់ខ្មែរក្រហមដែលទទួលបន្ទុកសន្តិសុខផ្ទៃក្នុងនៅរបបកម្ពុជាប្រជាធិបតេយ្យ ។

ឆ្លើយ តបថា លោក បានដឹងពីការធ្វើដំណើររបស់លោកស្រី ចារីស ប៉ុន្តែបានពន្យល់ថា លោក និង លោកស្រី ចារីស មានគំនិតផ្សេងគ្នា និងលោកមិនច្បាស់ទេថា តើលោកស្រីប្រមូលឯកសារអ្វីខ្លះទេ នៅប្រទេសវៀតណាមនោះ ។ លោកបានកត់សម្គាល់ថា លោកសង្ស័យថាលោកស្រី ចារីស មាននៅ កាន់កាប់ឯកសារខ្លះពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់មកលោក ឆាំង យុ ផ្តល់សក្ខីកម្មថា តួនាទី របស់លោកស្រី ចារីស គឺជាអ្នកផ្តល់ប្រឹក្សាដើម្បីបង្រៀនបុគ្គលិកក្នុងការបញ្ចូលទិន្នន័យទៅក្នុងប្រពន្ធ័ ទិន្នន័យ ប៉ុន្តែលោកជឿដែរថា លោកស្រីក៏ស្វែងរកការប្រមូលឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ផងដែរ ក្រៅពីតួនាទីការងាររបស់លោកស្រី ។ លោក ឆាំង យុ បន្ទាប់មកបានឲ្យដឹងថា លោកមិន ដែលបានសួរលោកស្រី ចារីស ពីឯកសារអ្វីខ្លះដែលលោកស្រីបានប្រមូលនៅប្រទេសវៀតណាមទេ ប៉ុន្តែ លោកស្រីបានប្រាប់លោក ឆាំង យុ ថា លោកស្រីបានប្រមូលឯកសារបោះពុម្ពពីប្រទេសវៀត ណាម ដែលរួមមានសៀវភៅជាច្រើនដែលសព្វថ្ងៃរក្សាទុកបណ្ណាល័យនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្រោយមក លោក ឆាំង យុ ត្រូវបានសួរពីឯកសារនានាទាក់ទងនឹងតុលាការបដិវត្តន៍ប្រជាជន បច្ចុប្បន្នមានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាឬទេ? លោក ឆាំង យុ ឆ្លើយតបថា ជាដំបូង ក្មួយរបស់លោកបាននាំយកឯកសារមួយចំនួនមកឲ្យលោកផ្ទាល់ដោយសារដឹងថា លោកធ្វើការទាក់ទង នឹងការងារនេះ ។ លោកក៏ចាប់ផ្តើមប្រមូលឯកសារដែលជាប់ទាក់ទងនឹងតុលាការនេះ ដែលបានត្រូវ រក្សាទុកនៅក្រសួងឃោសនាការ និងព័ត៌មាន ។ បន្ទាប់មកលោក ប៉ាវ សួរសំណួរទាក់ទងទៅនឹងអត្ថបទ មួយដែលលោកបានសរសេរជាមួយលោកបណ្ឌិត ចន ឆរឆីអារី ដែលមានចំណងជើងថា “ការចង ក្រងឯកសារពីបទឧក្រិដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ” ។ លោក ឆាំង យុ ដំបូងត្រូវបានសួរអំពី អត្ថបទនោះ ដែលអះអាងថា បញ្ហាចម្បងនៃតុលាការបដិវត្តន៍ប្រជាជននោះគឺការលម្អៀងខាងនយោ បាយ ។ លោក ឆាំង យុ ចាប់ផ្តើមឆ្លើយដោយធ្វើការកត់សម្គាល់ថា អត្ថបទនេះដំបូងឡើងសរសេរ ដោយ លោកបណ្ឌិត ឆរឆីអារី ដែលកត់សម្គាល់ខាងក្រោមថា រួមនិពន្ធដោយ ចន ឆរឆីអារី និង ឆាំង យុ ហើយដែលលោក បណ្ឌិត ឆរឆីអារី បានសរសេរអត្ថបទនេះបន្ទាប់ពីធ្វើការសម្ភាសន៍ជា មួយលោក ឆាំង យុ ។ បន្ទាប់មកលោកបានពន្យល់ថា ឯកសារពីរបបខ្មែរក្រហមនានាត្រូវបានបំផ្លាញ បន្តិចក្រោយពីរបបនេះរលំរលាយ ។ លោកបានឲ្យដឹងថា នេះគឺជាសំណាងអាក្រក់មួយពីព្រោះ លោក ជឿថារាល់ឯកសារនីមួយៗពីសម័យខ្មែរក្រហម គឺមានប្រយោជន៍ស្មើគ្នានឹងផ្ទាំងថ្មបុរាណអង្គរវត្តមួយ ដុំដែរ ។ បន្ទាប់មកលោក ឆាំង យុ ថ្លែងថា លោកមានការច្រឡំក្នុងខណៈនេះថា ហេតុអ្វីបានជា អត្ថបទនេះ ធ្វើឲ្យមានការភ្ញាក់ផ្អើលដល់មនុស្សនៅតុលាការម៉្លេះ ពីព្រោះវាត្រូវបានបោះពុម្ពតាំងពីឆ្នាំ ២០០៤ ។ លោកថ្លែងថា លោកបានប្រាប់រាល់ភាគីទាំងអស់ថា ដូចជាខាងព្រះរាជអាជ្ញាថា សៀវ

ភៅនេះមានអត្ថបទនេះដែលហើយមានដាក់លក់ ប៉ុន្តែព្រះរាជអាជ្ញាដែលបានឲ្យដឹងថា ពួកគេគ្មានលទ្ធភាពទិញសៀវភៅទេ។[៣] ហេតុដូនេះ លោក ឆាំង យុ បានផ្តល់មួយច្បាប់ទៅរាល់ភាគីទាំងអស់ អ.វ.ត.ក ។

## អៀង សារី សុំលះបង់សិទ្ធិចូលរួមស្តាប់សវនាការ និងសុំស្តាប់នៅក្នុងមន្ទីរឃុំឃាំង

នៅក្នុងចំណុចនេះ មុនពេលសម្រាក លោក អង្គ ឧត្តម ក្រុមការពារមេធាវី អៀង សារី បានដាក់ពាក្យស្នើសុំដូចសព្វដង សុំការអនុញ្ញាត អៀង សារី លះបង់សិទ្ធិចូលរួមស្តាប់នៅបន្ទប់សវនាការដើម្បីទៅស្តាប់ដំណើរការតាមប្រពន្ធ័សោតទស្សន៍ដោយសារបញ្ហាសុខភាព។ ប្រធានអង្គជំនុំជម្រះ និល ណុន បានអនុញ្ញាតការស្នើដូចសព្វមួយដង ហើយបានរំឭកដាក់ជូននូវឯកសារជាលាយលក្ខណ៍អក្សរ ដែលចុះហត្ថលេខាដោយ អៀង សារី។ បន្ទាប់ពីឈប់សម្រាកពេលព្រឹក លោកប្រធានចៅក្រម និល ណុន បានណែនាំលោក ឆាំង យុ ប្រើឈ្មោះពិតប្រាកដរបស់ជនជាប់ចោទ និងកុំប្រើឈ្មោះបដិវត្តន៍របស់ពួកគេ ឬឈ្មោះហៅក្រៅរបស់គាត់ ក្នុងចម្លើយរបស់លោកដើម្បីធានាឲ្យមានការកត់ត្រាឲ្យបានច្បាស់។ បន្ទាប់មកអង្គជំនុំបានប្រាប់ លោក ប៉ាវ ដែលថា ក្រុមធាវី នួន ជា អាចផ្តល់ឱកាសឲ្យសួរសំណួររហូតដល់ ម៉ោង ២.៤០នាទី ល្ងាចដោយហេតុថា ក្រុមមេធាវីការពារក្តី អៀង សារី មិនបានរៀបចំសំណួរសួរលោក ឆាំង យុ។

## ការបន្តសាកសួរដោយក្រុមមេធាវីរបស់ នួន ជា

បន្ទាប់មក លោក ប៉ាវ បានត្រឡប់ទៅលើកពីរឿងអត្ថបទស្តីអំពី*“ការកត់ត្រាបទឧក្រិដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ”* ហើយសួរថា ហេតុអ្វីបានជាលោក ឆាំង យុ និង លោកបណ្ឌិត ឆរឆើអារីយល់ឃើញថា ការជ្រៀតជ្រែកផ្នែកនយោបាយជារឿងសំខាន់ក្នុងការខ្វះខាតនៃតុលាការបដិវត្តន៍ប្រជាជន។ លោក ឆាំង យុ បានឆ្លើយត្រឹមថា មជ្ឈមណ្ឌលឯកសារកម្ពុជា បានធ្វើការតស៊ូមតិក្នុងការបង្កើតឲ្យមានតុលាការឯករាជ្យមួយ។ ឆ្លើយតបទៅវិញ លោក ប៉ាវ បានសួរអំពីរឿងមុនដែលទាក់ទងទៅនឹងឯកសារនានាដែលត្រូវបានបោះចោលក្នុងទន្លេមេគង្គ។ លោក ឆាំង យុ បានឆ្លើយតបថា ប្រជាជនកម្ពុជាជាច្រើនបានសរសេរស្នើទៅកាន់រដ្ឋាភិបាលបង្កើតតុលាការមួយ។ នៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ព្យាយាមរក្សាទុកនូវឯកសារទាំងនេះ មជ្ឈមណ្ឌលត្រូវបានគេផ្តល់ដំណឹងថា

---

[៣] អត្ថបទនេះតាមពិតជាជំពូកមួយក្នុងសៀវភៅសរសេរដោយ ដាយ រាំដឺ-ណូហ្វែលស៍ និង ប៉ែត វ៉ាន់ស្កាក់ និងអាចរកបាននៅក្នុងគេហទំព័រឃ្លាំមើលតុលាការកម្ពុជាតាមរយៈ

ពួកគេបានបោះឯកសារជាច្រើនទៅក្នុងទន្លេមេគង្គ។ លោក ឆាំង យុ បានផ្តល់សក្ខីកម្មបន្ថែមទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានបញ្ជីរាយនាមមន្ត្រីក្រសួង ធ្វើការទទួលខុសត្រូវខាងឯកសារនៅខេត្តស្ទឹងត្រែង នៅពេលនោះ។ លោក កត់សម្គាល់ថា បញ្ជីរាយនាមត្រូវបានផ្តល់ឲ្យដោយក្រសួងឃោសនាការផ្ទាល់ និង មិនបានរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាទេ។

បន្ទាប់មក លោក ប៉ាវ បានបែរទៅសួររឿងចម្លើយសារភាពរបស់ រស់ ញឹម[៨] ពីគុកទួលស្លែង និងសួរថ វមានចម្លើយសារភាពប៉ុន្មានខ្សែត្រូវបានដឹង។ លោក ឆាំង យុ បានពន្យល់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា ស្វែងរករាល់ចម្លើយសារភាពទាំងអស់ដែលអាចធ្វើទៅបាន ពីព្រោះនៅគុកទួលស្លែង រាល់អ្នកទោសទាំងអស់គឺត្រូវគេថតរូប និងចម្លើយសារភាពរបស់ពួកគេជាច្រើន ត្រូវតែមានទៅតាមច្បាប់ជាធម្មតា។ ជាពិសេសករណី រស់ ញឹម លោក ឆាំង យុ បានឲ្យដឹងថា លោកជឿថា ចម្លើយសារភាពរបស់គាត់ច្បាប់ចម្លងមួយច្បាប់មាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែ មិនច្បាស់ថា តើមជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញច្បាប់បន្ថែមឬខ្សែផ្សេងទៀតនៃចម្លើយសារភាពរបស់ ញឹម រស់ ជាពិសេសឬទេ?

លោក ប៉ាវ បានសួរអំពីរឿងបណ្ណុំឯកសាររបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ដែលយោងទៅនឹងការផ្តល់សក្ខីកម្មរបស់លោកនាយករង វ៉ាន់ថាន់ ពៅដារ៉ា។ លោក ឆាំង យុ បានឲ្យដឹងថា បណ្ណុំឯកសារផ្ទាល់របស់ព្រះអង្គ មានពេលម្តងនោះ អាចចូលមើលបានលើប្រពន្ធ័អ៊ីនធឺណែត ហើយមជ្ឈមណ្ឌលឯកសារកម្ពុជា បានបោះពុម្ពជាក្រដាសឯកសារខ្លះពីបណ្ណុំឯកសារនោះខណៈដែលវានៅមាន។ លោកបានឲ្យដឹងបន្ថែមទៀតថា បើតាមលោកដឹង ឯកសារជាក្រដាសត្រូវបានបញ្ជូនទៅប្រទេសប៊ែលស៊ិច។

នៅសវនាការពេលព្រឹក លោក ប៉ាវ បានសួរលោក ឆាំង យុ អំពីទាក់ទងនឹងគម្រោង "គម្រោងជំរុញឲ្យមានការទទួលខុសត្រូវ" នៅក្នុងកថាមុខសរសេរដោយលោកក្នុងសៀវភៅ "បុគ្គល៧នាក់ត្រូវ កាត់ទោស" សរសេរដោយ ស៊ីវ ហេឌើ និង ទីតេមូរ។ លោក ប៉ាវ សួរ លោក ឆាំង យុ តើមជ្ឈមណ្ឌលវាយតម្លៃឯកសារភស្តុតាងដូចដែលបានអះអាងនៅក្នុងកថាមុខនោះយ៉ាងដូចម្តេច? លោក ឆាំង យុ ឆ្លើយតបថា អ្នកនិពន្ធនានានឹងទទួលខុសត្រូវនូវការវិភាគនៅក្នុងអត្ថបទ និងបញ្ជាក់ការថ្លែងម្តងទៀតរបស់លោកកាលពីសវនាការលើកមុនៗថា "ច្បាប់មិនអាចមានសិទ្ធិផ្តាច់មុខលើពាក្យភស្តុតាងទេ" ។ លោកបានបន្ថែមទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាខិតខំដើម្បីឲ្យមានការផ្សះផ្សាជាតិ

---

[៨] រស់ ញឹម ជា លេខាបក្សនៃភូមិភាគខាងពាយ័ព្យក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់តាំងពីឆ្នាំ ១៩៧៧ នៅពេលដែលគាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់ ស-២១ និងចុងក្រោយត្រូវសម្លាប់។

នៅប្រទេសកម្ពុជាជាទូទៅ ហើយមិនមែនតែបង្កើតឡើងពិសេសសម្រាប់តែគាំទ្រការបង្កើតតុលាការមួយប៉ុណ្ណោះទេ ។

បន្ទាប់មក លោក ប៉ាវ បានសួរ លោក ឆាំង យុ អំពី បញ្ជីឈ្មោះអតីតមន្ត្រីនៅក្នុងបក្សកម្មុនីស្តកម្ពុជាដែលសៀវភៅ «បេក្ខជន៧រូបដែលត្រូវធ្វើការកាត់ទោស» បានបង្ហាញឲ្យដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើត និងឧបសម្ពន្ធ័រៀបរាប់ពីព័ត៌មានពីបុគ្គលនានាដែលបានចាត់ទុកពួកគេក្នុងការប្រព្រឹត្តបទល្មើស ។ លោក ឆាំង យុ បានឲ្យដឹងថា លោក មិនបានចាំពីឈ្មោះបុគ្គលទាំង១០នាក់នោះទេ ប៉ុន្តែបានឲ្យដឹងថា នៅក្នុងចំណោមពួកគេទាំងនោះរួមមាន នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ។ បន្ទាប់មក លោក ប៉ាវ បានសួរពីអ្នកដែលនៅសល់ក្នុងបញ្ជីនោះ ដែលធ្វើឲ្យមានការជំទាស់ពីព្រះរាជអជ្ញា ដែលអះអាងថា វាមិនទាក់ទងទៅនឹងរឿងក្ដីទេ ។

អង្គជំនុំជម្រះយល់ស្របនឹងការជំទាស់ និងបង្គាប់លោក ឆាំង យុ មិនចាំបាច់ឆ្លើយទៅនឹងសំណួរនេះទេ ។ លោក ប៉ាវ បានបន្តទៅពិភាក្សាពីសៀវភៅមួយទៀតដែលសរសេរដោយ ចាយ៉ាវាំជី-នោហ្គលស៍ និង អាន ហេនឌែល មានចំណងជើងថា «ប្រល័យពូជសាសន៍ៈ នរណាខ្លះជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលត្រូវកាត់ទោសសារសំខាន់នៃសំណុំរឿង០០២នៃអ.វ.ត.ក» ។ លោក ឆាំង យុ បានកត់សម្គាល់ថា លោក«ចូលចិត្ត»សៀវភៅនេះយ៉ាងខ្លាំង និងពន្យល់ថា វាំជី-នោហ្គលស៍ ជាសាស្ត្រចារ្យ និង ហេនឌែល ជាទីប្រឹក្សាច្បាប់ម្នាក់របស់មជ្ឈមណ្ឌលដែលបានបំពេញការងារទាក់ទងនឹងតុលាការ ។ ក្រោយមកលោក ប៉ាវ បានអានព្ទៗពីផ្នែកមួយ នៅក្នុងកថាមុខពីសៀវភៅនោះដែលសរសេរឡើងដោយលោក ឆាំង យុ ថា អ្នកដែលជាមេដឹកនាំទាំងឡាយនៃរបបកម្ពុជាប្រជាធិបតេយ្យគឺដែលកំពុងតែទទួលខុសត្រូវនូវបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅក្នុងរបបនោះ មិនមែនគ្រាន់តែមន្ត្រីនៅតាមតំបន់នានាប៉ុណ្ណោះទេ ។ លោក ប៉ាវ បានឲ្យដឹងថា កថាមុខដែលលោក ឆាំង យុ បានសរសេររួចមកហើយនេះ គឺបានធ្វើការសន្និដ្ឋានសរុបដោយផ្ទាល់ដោយទាញយកពីភស្តុតាងអំពីទោសកំហុសនៃជនជាប់ចោទនៅក្នុងសំណុំរឿង០០២ និងស្នើឲ្យលោក ឆាំង យុ ធ្វើការពន្យល់ពីការថ្លែងនានារបស់លោក ។ នេះបង្កឲ្យមានការជំទាស់មួយទៀតពីការមិនជាប់ពាក់ពន្ធ័ទៅនឹងប្រធានបទពីខាងព្រះរាជអាជ្ញា ។ លោក ប៉ាវ ឆ្លើយតបថា ការថ្លែងដូចនេះបង្ហាញថា លោក ឆាំង យុ មានភាពលម្អៀងទៅលើជនជាប់ចោទ ។ លោកថែមទាំងបានលើកឡើងថា គំនិតលម្អៀងបែបនេះគឺ ពិសេសមានបញ្ហានៅពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជា«អ្នករក្សាទុក»ឯកសារជាច្រើនដែលដាក់ជូនអ.វ.ត.ក ។ លោកប្រធានអង្គជំនុំជម្រះ និល ណុន យល់ស្របលើការជំទាស់និងបានបង្គាប់ឲ្យលោក ប៉ាវ សួរនៅក្នុងប្រធានបទនិងកំណត់សំណួររបស់លោកឲ្យបានសមស្រប ។

ក្រោយមកទៀតលោក ប៉ាវ បានសួរអំពីសំបុត្រការអនុញ្ញាតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានពីរដ្ឋាភិបាលកម្ពុជា និងជាពិសេសពីវិសាលភាពដែលលិខិតអនុញ្ញាតនោះផ្ដល់ឲ្យ ។ លោក ឆាំង យុ បានឆ្លើយថា លិខិតនោះអនុញ្ញាតឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកឯកសារនានានៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែជួនកាលមជ្ឈមណ្ឌលត្រូវធ្វើការពិភាក្សាជាមួយស្ថាប័ន ឬក៏ភ្នាក់ងារផ្សេងៗ និងអនុវត្តតាមដំណើរការនីតិវិធីបន្ថែមនានា ដើម្បីអាចបានចូលរកឯកសារមួយចំនួន ។ ក្រោយមកលោក ប៉ាវ សួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជាដែលអនុញ្ញាតចូលទៅរកក្នុងបណ្ណសារដ្ឋាននៃគណបក្សប្រជាជនកម្ពុជាដែរឬទេ? សំណួរនេះធ្វើឲ្យមានការជំទាស់ពីព្រះរាជអាជ្ញា ដែលលើកឡើងថា ក្រុមមេធាវីការពារបានកំពុងតែ«ដដឹក» និងស្វែងរកនូវព័ត៌មានដែលមិនជាប់ពាក់ពន្ធ័ទាល់តែសោះនឹងដំណើរការរឿងក្ដីដែលអាចនឹងផ្ដល់នូវការមិនយល់ស្របពីព័ត៌មាន ។ លោក ប៉ាវ ឆ្លើយតបដោយអះអាងថា ព្រះរាជអាជ្ញាបានសួរលោក ឆាំង យុ ពីការស្រាវជ្រាវដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅក្នុងបណ្ណសារដ្ឋានរបស់គណបក្សប្រជាជនកម្ពុជា ហេតុដូច្នេះហើយខាងក្រុមការពារក៏អាចមានឱកាសសួរដូចគ្នាដែរ ។ អង្គជំនុំជម្រះបានពន្យល់ដោយសង្ខេបមុននឹងធ្វើការមិនយល់ស្របនឹងការជំទាស់នេះ ។

បន្ទាប់មក លោក ឆាំង យុ ឆ្លើយតបថា លោក«សប្បាយរីករាយ»នឹងឆ្លើយទៅនឹងសំណួរនេះ ។ លោកផ្ដល់សក្ខីកម្មថា ដំបូងឡើងមានគណៈកម្មាធិការមួយត្រូវបានបង្កើតឡើងដោយមានកិច្ចសហការរវាងប្រទេសកម្ពុជា វៀតណាម និងឡាវ ដើម្បីចងក្រងប្រវត្តិសាស្ត្រនៃការធ្វើបដិវត្តន៍នៅក្នុងប្រទេសទាំងនេះ ។ លោក ឆាំង យុ បានឲ្យដឹងថាលោកព្យាយាមរកមើលឯកសារទាក់ទងនឹងព័ត៌មានពីគណៈកម្មាធិការរួមគ្នានេះ និងការងាររបស់ពួកគេ ប៉ុន្តែមិនបានប្រទះឃើញឯកសារនានាដែលបង្កើតឡើងដោយគណៈកម្មាការនេះទេ ពីព្រោះឯកសារទាំងនោះនៅបែកខ្ញែកគ្នានៅក្នុងប្រទេសទាំងបីនេះ ។ លោកក៏បានបន្ថែមទៀតថា ដូចដែលមាននៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអាចទាក់ទាញការចាប់អារម្មណ៍ពីគ្រប់ភាគីនៅ អ.វ.ត.ក ។ ឆ្លើយតបទៅនឹងសំណួរផ្សេងទៀត លោក ឆាំង យុ ពន្យល់ថា «បណ្ណសារដ្ឋានដើមរបស់គណបក្សប្រជាជនកម្ពុជា»បានបិទនៅក្នុងឆ្នាំ១៩៩៣ ហើយបណ្ណសារដ្ឋាននេះដែលបានមកពីការងាររបស់គណកម្មាធិការរួមនេះ ។

ក្រោយមក លោក ប៉ាវ បានសួរថា តើគណបក្សប្រជាជនកម្ពុជាមានកាន់កាប់ឯកសារនានាទាក់ទងនឹងរបបកម្ពុជាប្រជាធិតេយ្យឬទេ? លោក ឆាំង យុ ឆ្លើយតបថា នៅឆ្នាំ ២០០៥ លោកបានសរសេរសំបុត្រជាភាសាខ្មែរ អង់គ្លេស និងបារាំង ស្នើសុំឲ្យមានការផ្ញើឯកសារនានាទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យផ្ញើទៅ អ.វ.ត.ក ។ លោក ឆាំង យុ បានឲ្យដឹងថា ពីព្រោះតែបណ្ណសារ

ដ្ឋានរបស់គណបក្សប្រជាជនបានបិទ លោកសង្ស័យថាមានមន្ត្រីរដ្ឋាភិបាលខ្លះអាចមានឯកសារពីរបបនោះ ប៉ុន្តែសព្វថ្ងៃនេះគ្មានបណ្ណសារដ្ឋានរបស់គណបក្សប្រជាជនទៀតទេ។ ក្រោយមកលោក ប៉ាវ សួរពីឯកសារដែលផ្តល់ឲ្យដោយលោក ខៀវ កញ្ញារិទ្ធិ[៥] និងសួរតើមជ្ឈមណ្ឌលឯកសារកម្ពុជាមានបានទទួលរាល់ឯកសារនានា ពីរបបកម្ពុជាប្រជាធិតេយ្យពីលោក ដែរឬទេ? លោក ឆាំង យុ បានឆ្លើយតបថា លោក ខៀវ កញ្ញារិទ្ធិ បានជូនដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាថា លោកបានប្រគល់រាល់ឯកសារពីរបបខ្មែរក្រហមដែលលោកមាន ប៉ុន្តែ លោកមិនមានវិធីអ្វីនឹងបញ្ជាក់ពីការពិតនេះទេ។

នៅក្នុងចំណុចនេះ អង្គជំនុំជម្រះរៀបចំនឹងសម្រាកអាហារថ្ងៃត្រង់ដូចសព្វដង មេធាវីការពារក្តី នួន ជា បានជូនដំណឹងទៅអង្គជំនុំជម្រះថា នួន ជា មានបំណងលះបង់សិទ្ធិនៅក្នុងការតាមដានស្តាប់សវនាការនៅក្នុងសាលសវនាការ និងសុំទៅតាមដានស្តាប់នៅបន្ទប់ឃុំឃាំងតាមរយៈប្រព័ន្ធសវនទស្សន៍វិញ។ លោកប្រធាន អង្គជំនុំជម្រះ និល ណុន បានអនុញ្ញាតតាមសំណើនេះដូចសព្វដង។

បន្ទាប់ពីការឈប់សម្រាកអាហារថ្ងៃត្រង់ ក្រុមមេធាវីអន្តរជាតិការពារក្តី នួន ជា លោក ហ្សាស្តេ ប៉ាវ បានសួរសំណួរជាច្រើនទៀតទៅកាន់ លោក ឆាំង យុ មុននឹងផ្តល់វេទិកាទៅឲ្យមេធាវីជាតិសហសវិករបស់លោក សុន អរុណ។ ដំបូង លោក ប៉ាវ បានសួរអំពីអត្ថបទដែលសរសេរ ដោយលោក ស្ទីវ ហេឌើ ដែលបានឲ្យសរសេរនៅក្នុងកំណត់យោងថា មានភស្តុតាងដែលប្រាប់ថា លោកហេង សំរិន និង ជា ស៊ីម នៅក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។[៦]

លោក ប៉ាវ បានប៉ុនប៉ងចង់សួរលោក ឆាំង យុ ថា មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានអនុញ្ញាតឲ្យចូលទៅរកមើលឯកសារនានានៅក្នុងបណ្ណសារដ្ឋានរបស់គណបក្សប្រជាជន ក្រែងលឯកសារទាំងនោះ មានព័ត៌មានទាក់ទងនឹងបទឧក្រិដ្ឋនានាដែលអាចនឹងប្រព្រឹត្តដោយ លោក ហេង សំរិន និង ជាស៊ីម។ មុនពេល លោក ឆាំង យុ អាចនឹងឆ្លើយតបនឹងសំណួរនេះ លោកប្រធានអង្គជំនុំជម្រះ និលណុន កាត់និងថ្លែងថា សំណួរនេះមិនសមរម្យហើយនិងមិនជាប់ពាក់ពន្ធ័ទៅនឹងរឿងក្តីទេ ហើយសារជាថ្មីម្តងទៀត រំឭកដល់លោក ប៉ាវ ឲ្យកំណត់សំណួរដែលជាប់ទាក់ទងទៅនឹងប្រធានបទថ្ងៃនេះ។

លោក ប៉ាវ បានឆ្លើយតបដោយលើកឡើងថា វាជាការចាំបាច់ក្នុងការស្វែងយល់ឲ្យស៊ីជម្រៅទៅនឹងការងារទាក់ទងនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាពិសេស ដើម្បីលាតត្រដាងការពិតថារដ្ឋាភិបាលកម្ពុជាពិតជាមានការជ្រៀតជ្រែកនៅក្នុងកិច្ចការងាររបស់ អ.វ.ត.ក។ បន្ទាប់មក លោក ប៉ាវ

[៥] វាហាក់ដូចជា អ្នកដែលគេកំពុងតែពិភាក្សានេះគឺជារដ្ឋមន្ត្រីក្រសួងព័ត៌មាន ប៉ុន្តែការពិតនេះ មិនត្រូវគេលើកយកនិយាយនៅក្នុងសាលសវនការទេ។

[៦] ហេង សំរិន សព្វថ្ងៃជាប្រធានរដ្ឋសភាជាតិកម្ពុជា និង ជា ស៊ីម ជា ប្រធានព្រឹទ្ធសភា កម្ពុជា។

បានកត់សម្គាល់ថា ជាពិសេស«ការជ្រៀតជ្រែក»របស់រដ្ឋាភិបាលក្នុងការ«តែងតាំងចៅក្រម ស៊ើបអង្កេតអន្តរជាតិ» ដែលជាចៅក្រមស៊ើបអង្កេតបំរុង ឡូរិន ខាសពើ អាន់ស្មើត ។

លោកប្រធាន និល ណុន ហាក់ដូចជាស្រលាំងកាំងដោយការឆ្លើយតបរបស់លោក ប៉ាវ ហើយក៏បានបដិសេធម្តងទៀត ដោយរិះគន់លោក ប៉ាវ ឲ្យឈប់បន្តសំណួរដែលទាក់ទងនឹងបញ្ហាក្រៅពីវិសាលភាពនៃដំណើរការប្រមូលឯកសារ និងដំណើរការឯកសារកុំឲ្យមានការបង្កាប់សារជាថ្មីពីអង្គជំនុំជម្រះទៀត។ បន្ទាប់មក លោក ប៉ាវ លោកនឹងបន្តលើប្រធានបទផ្សេងពីភស្តុតាងបញ្ជាក់ថា អ្នកនយោបាយខ្មែរមានការជាប់ពាក់ពន្ធ័នឹងបទឧក្រិដ្ឋនានានិងសួរពីការលើកឡើងរបស់ ស៊ីវ នៅក្នុងអត្ថបទដែលថា មានការកាប់សម្លាប់ជាច្រើនធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលបានអនុវត្តដោយមន្ត្រីថ្នាក់ក្រោមនៃបក្សកម្មុយនីសកម្ពុជានៅតាមមូលដ្ឋាន «ដោយគ្មានបញ្ជាពិតប្រាកដពីថ្នាក់ដឹកនាំបក្សកម្មុយនីស្តកម្ពុជាទេ» ។ លោក ឆាំង យុ ឆ្លើយតបថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសមនុស្សជាង ១០០០នាក់ ប៉ុន្តែគ្មាននរណាម្នាក់បានសារភាពថា ខ្លួនបានសម្លាប់មនុស្សទេ។ លោក ឆាំង យុ បានបន្តទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនយល់ស្របតាមទ្រឹស្តីរបស់លោក ហេឌឺ ទេ បើដោយគ្រាន់តែយោងតាមការសាកសួរដើម្បីរកឲ្យឃើញថាជនណាម្នាក់បានប្រព្រឹត្តអំពើឃោរឃៅនោះ ។

ក្រោយមក លោក ប៉ាវ បានសួរទៅលោក ឆាំង យុ ពីការសន្និដ្ឋានសរុបរបស់លោក ហេឌឺ ថា ការទទួលខុសត្រូវដែលត្រឹមត្រូវពិតប្រាកដមួយនៅក្នុងរបបខ្មែរក្រហមគួរតែតម្រូវឲ្យមានការស៊ើបអង្កេត និងកាត់ទោសអតីតមន្ត្រីថ្នាក់ក្រោម បក្សកម្មុយនីសកម្ពុជាតាមខ្សែសង្វាក់នៃការបញ្ជារួមទាំងហៅថា «មន្ត្រីតូចតាច» ដោយមិនលើកលែងនូវមន្ត្រីដែលមានដំណែងនៅក្នុងរដ្ឋាភិបាលសព្វថ្ងៃផង ។ សំណួរនេះធ្វើឲ្យមានការជំទាស់ពីខាងសហព្រះរាជអាជ្ញាម្តងទៀតថា វាមិនជាប់ពាក់ពន្ធ័នឹងប្រធានបទ ។

បន្ទាប់មក លោក ប៉ាវ បានបញ្ជាក់ថាលោកនឹងផ្តល់នាទីទៅឲ្យសហសវិកជាតិរបស់លោក ប៉ុន្តែលោកលើកឡើងថា ក្រុមការពារក្តីឲ្យ នួន ជា មានជំហរថា អង្គជំនុំជម្រះគ្រាន់តែអនុញ្ញាតឲ្យក្រុមនេះ «សួរសើៗ»លើប្រធានបទនៃភាពលម្អៀងជាចម្បង លើផ្នែកខ្លះនៃមជ្ឈមណ្ឌលឯកសារកម្ពុជាប៉ុណ្ណោះ ។

ក្នុងអំឡុងពេលធ្វើការកត់សម្គាល់នេះ លោកប្រធាន និល ណុន ជាថ្មីម្តងទៀតបានកាត់ និងរំឭកលោក ប៉ាវ ពីវិសាលភាពនៃកម្មវិធីចោទសួរសម្រាប់ថ្ងៃនេះ ដោយលើកឡើងថា ប្រសិនបើក្រុមមេធាវីការពារ នួន ជា មិនអាចសួរនៅក្នុងប្រធានបទបានទេអង្គជំនុំជម្រះនឹងបញ្ចប់ការសួររបស់ក្រុមនេះ។ លោក ប៉ាវ ឆ្លើយតបដោយលើកឡើងថា លោកនឹងប្រគល់នាទីនេះឲ្យទៅលោក សុន អរុណ ប៉ុន្តែលោកសូមស្នើការសន្និដ្ឋានពីរជូនអង្គជំនុំជម្រះ ។ ទី១ លោក ប៉ាវ ស្នើឲ្យអង្គជំនុំជម្រះបង្គាប់ឲ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់នូវព័ត៌មានជាក់លាក់ដែលទាក់ទងនឹងឯកសារនានាដែលខ្លួនកាន់កាប់ ដែលជាឯកសារដើមទៅឲ្យតុលាការ ។ ទី២ លោក ប៉ាវ ស្នើលោក ឆាំង យុ មកធ្វើសក្ខីកម្មម្តងទៀតក្នុងនាមជាសាក្សីក្នុងការពិភាក្សាពីប្រធានបទមុន ដែលមិនបានលើកឡើងដោយអង្គជំនុំជម្រះពីការជ្រៀតជ្រែកនយោបាយ និងភាពលម្អៀងជាចម្បង ដោយហេតុថា ប្រធានបទនេះមិនបានឲ្យដឹងពិតប្រាកដ ដោយសារការកំណត់វិសាលភាពនៃការសួរសំណួរនៅពេលនេះ ។ លោក ប៉ាវ ចាប់ផ្តើមដោយលើកឡើងថា "វាកម្រណាស់" ដែលអង្គការឯកជនមួយមានភស្តុតាងជាច្រើនដែល ប្រមូលនៅក្នុងតុលាការឧក្រិដ្ឋកម្ម ។ នៅពេលនោះដែរ លោកប្រធានចៅក្រម និល ណុន បានកាត់ ម្តងទៀត ហើយលើកឡើងថា ក្រុមមេធាវីការពារមិនមាននាទីក្នុងការធ្វើការសន្និដ្ឋានជាទូទៅនៅពេលនោះទេ ។

ក្រោយមក លោក ប៉ាវ ស្នើផ្តល់នាទីទៅឲ្យលោកសហសវិកជាតិរបស់លោក សុន អរុណ ដែលបន្ត សំណួរទៅ លោក ឆាំង យុ ។ នៅត្រង់ចំណុចនេះ លោកចៅក្រមបានពន្យល់ជាសង្ខេប និងលោកចៅក្រម ហ្សង់មាក ឡាវែន៍ បានសួរសំណួរខ្លះទៅក្រុមមេធាវីការពារក្តី នួន ជា ។ លោកចៅក្រមដំបូងសួរថា លោក ប៉ាវ ថាតើសំណើសុំព័ត៌មានរបស់ខាងមេធាវីការពារពីមជ្ឈមណ្ឌលឯកសារកម្ពុជា មិនដែលទទួលបានទេ ឬអ្វីក្នុងអំឡុងដំណាក់កាលធ្វើការស៊ើបអង្កេតក្នុងសំណុំរឿង០០២ នេះ? បន្ទាប់មកលោក ចៅក្រម ឡាវែន៍ យោងទៅតាម អ.វ.ត.ក វិធានផ្ទៃក្នុងមាត្រាទី៨៧ ដែលតម្រូវឲ្យភាគីមួយដើម្បីបង្ហាញថា ភស្តុតាងថ្មីដែលនឹងត្រូវដាក់ក្នុងការកាត់ក្តីមិនមានពីដំបូង ។

បន្ទាប់មក លោក ប៉ាវ បានឆ្លើយតបថា ក្រុមការពារក្តីឲ្យ នួន ជា ទើបតែដឹងច្បាស់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា មានព័ត៌មានទាក់ទងទៅនឹងប្រភពឯកសារនៅពេលសាកសួរក្នុងសវនាការកាលពីព្រឹកមិញ ។ លោកក៏បានបន្ថែមទៀតថា តាមពិតនេះជាតួនាទីរបស់ការិយាល័យសហព្រះរាជអាជ្ញា និងឬចៅក្រមស៊ើបអង្កេតទេ ក្នុងការដាក់ព័ត៌មានពីប្រភពឯកសារនានា និងនេះមិនមែនជាតួនាទីរបស់ខាងមេធាវីការពារទេនៅពេលនោះ ។ លោកតំណាងសហព្រះរាជអាជ្ញា ធារីក អាបឌូលហក បានឆ្លើយតប ដោយផ្តល់នូវការសង្ខេបពីដំណើរការប្រមូលភស្តុតាងនៅ អ.វ.ត.ក ដែលគិតចាប់តាំងពីឆ្នាំ២០០៩មកម្ល៉េះ ។ លោកសន្និដ្ឋានថាការិយាល័យសហព្រះរាជអាជ្ញាបានដាក់ជូនសំណើភស្តុតាងទៅរាល់ភាគីទាំងអស់យ៉ាងត្រឹមត្រូវជាមុន ហើយថាអង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតលើឯកសារទាំងនោះហើយ គ្រាន់តែត្រូវការបញ្ជាក់ទាក់ទងនឹងការទទួលស្គាល់ ។ លោក ប៉ាវ បានឆ្លើយថា បន្ទុកនេះគឺជារបស់ការិយាល័យព្រះរាជអាជ្ញាដើម្បីឲ្យមានឯកសារដើមសុក្រិត្យ និងលើកឡើងថា មេធាវីការពារក្តីមិនមែនចេះតែទទួលយកព័ត៌មានងាយៗនោះទេ ។ លោកក៏បានបន្ថែមទៀតថា មេធាវីការពារក្តីតាមរយៈការស្នើសុំនេះ តាមការពិតបានជួយខាងសហព្រះរាជអាជ្ញាពីដំណើរការរកសុក្រិត្យភាពនៃឯក

សារ ។ បន្ទាប់ពីពន្យល់បន្តិច អង្គជំនុំជម្រះបានប្រកាសថា ខ្លួនមិនអាចចេញការសម្រេចមួយភ្លាមៗពីបញ្ហានេះទេ ប៉ុន្តែនឹងធ្វើការសម្រេចនៅ«ពេលថ្ងៃខាងមុខ» ។ នាទីនេះបានផ្តល់ឲ្យទៅខាងមេធាវីជាតិ លោក សុន អរុណ ដើម្បីបន្តការសាកសួរសម្រាប់ក្រុមការពារក្តី នួន ជា ។

## លោក សុន អារុណ ធ្វើការសរុបនូវសំណួររបស់ក្រុមការពារក្តី នួន ជា

ដំបូងឡើង លោក សុន អរុណ បានសួរថាតើមជ្ឈមណ្ឌលឯកសារកម្ពុជា មានឯកសារដើម ឬក៏ឯកសារចម្លង។ លោក ឆាំង យុ ឆ្លើយថា មជ្ឈមណ្ឌលឯកសារកម្ពុជា មានទាំងឯកសារដើម និងថតចម្លងពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបទៅនឹងសំណួរបន្ថែមទៀតលោក ឆាំង យុ បាន បញ្ជាក់ឡើងវិញពីការផ្តល់សក្ខីកម្មមុនៗ ដោយពន្យល់ពីហេតុដូចម្តេចបានជាលោកអះអាងថា ឯកសារ សុទ្ធតែជាឯកសារពិត និងហេតុអ្វីបានជាលោកជឿថា ពិតវាពិបាកនឹងធ្វើការក្លែងបន្លំឯកសារដែលបាន ធ្វើឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យណាស់ ។ បន្ថែមពីចម្លើយនេះ លោក សុន អរុណ បន្ត សំណួរលោក ឆាំង យុ ពីប្រភេទឯកសារជាក់លាក់មួយចំនួន ដូចជា ឯកសារសរសេរដោយដៃនៅ ក្នុងរបបនេះ និងជីវប្រវត្តិផ្សេងៗ ហើយថាតើពួកគេអាចធ្វើការបន្លំបានដែរឬទេ? សំណួរនេះ គឺ ជាន់គ្នាទៅនឹងសំណួរមុនៗដែលសួរលោក ឆាំង យុ នៅក្នុងថ្ងៃទីបីនៃការធ្វើសក្ខីកម្មរបស់លោក ហើយ លោក ឆាំង យុ បានបញ្ជាក់ម្តងទៀតពីហេតុផលដែលលោកជឿថា វាពិបាកនឹងធ្វើការក្លែងបន្លំឯកសារនានាដែលធ្វើឡើងនៅក្នុងរបបនេះណាស់ ។

បន្ទាប់មក លោក សុន អរុណ បានសួរពីត្រារបស់មន្ត្រី និងការកត់សម្គាល់ផ្សេងទៀតលើ ឯកសាររបបកម្ពុជាប្រជាធិបតេយ្យ ។ លោក ឆាំង យុ ឆ្លើយតបថា ការអានឯកសារជាចំណង់ ចំណូលចិត្តមួយរបស់លោក ក្នុងចំណុចនេះការអានឯកសារហាក់ដូចជាស្វែងរកបាយញ៉ាំនៅឯការដ្ឋាន ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលលោក និង អ្នកដទៃទៀតកំពុងតែអត់ឃ្លាន ។

ក្រោយមក លោក សុន អរុណ បានសួរលោក ឆាំង យុ ថាតើមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលឯកសារពីគ្រប់ជាន់ថ្នាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងដូចម្តេច នៅពេលដែលរបបនោះ មាន ការតឹងរឹងដូច្នេះ? លោក ឆាំង យុ ញញឹម និងលើកឡើងថា សំណួរនេះគឺជាសំណួរដ៏ល្អមួយ ហើយបន្ទាប់មកស្នើថា លោក សុន អរុណ សួរកូនក្តីលោក (នួន ជា) ពីបញ្ហានេះ ។ ក្រោយមក លោក ឆាំង យុ លើកឡើងបន្ថែមទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជា បានស្វែងរកឯកសារទាំងអស់ ដែលអាចរកបានទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងទោះបីជាមជ្ឈមណ្ឌលមានឯកសារជាច្រើន

ក៏ដោយឯកសារទាំងនេះគ្រាន់តែជា«ទឹកមួយដំណក់ក្នុងមហាសមុទ្រ»ទេ បើប្រៀបទៅនឹងឯកសារដែលបក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឡើងនោះ ។

## **លោក ឆាំង យុ បញ្ចប់ការផ្តល់សក្ខីកម្ម នៅថ្ងៃទីបី និងជាថ្ងៃបញ្ចប់នៃការផ្តល់សក្ខីកម្ម នៅ អ.វ.ត.ក**

លោក សុន អរុណ បានសួរថា ហេតុអ្វីបានជាមជ្ឈមណ្ឌលឯកសារកម្ពុជា នៅតែបន្តផ្តល់ឯកសារនានាមកឲ្យ អ.វ.ត.ក ប្រសិនបើលោក ឆាំង យុ គិតថាការផ្តល់ឯកសារទាំងនេះវា«ខុសនឹងច្បាប់» ។ លោក ឆាំង យុ បានញញឹមសារជាថ្មី ហើយឆ្លើយតបថា មជ្ឈមណ្ឌលផ្តល់ឯកសារដោយមិនគិតថ្លៃ ទៅគ្រប់ផ្នែកដោយមិនគិតថា ក្រុមណា បុគ្គលណាឡើយ ។ លោកផ្តល់សក្ខីកម្មបន្តទៀតថា មជ្ឈមណ្ឌលឯកសារកម្ពុជាគាំទ្រ អ.វ.ត.ក ហេតុដូច្នេះហើយនឹងប្រគល់ឯកសារអ្វីក៏ដោយទៅតាមសំណើរបស់តុលាការនេះ ។ បន្ទាប់មក លោក សុន អរុន បានសួរ លោក ឆាំង យុ ម្តងទៀតពីសៀវភៅ ទង់បដិវត្តន៍ នៃបក្សកុម្មុយនីស្តកម្ពុជា ហើយការទទួចរបស់ នួន ជា ថាមានឯកសារខ្លះត្រូវសរសេរដោយដៃ ។ លោក ឆាំង យុ បានឲ្យដឹងថា ប្រហែលជា «នួន ជា» យល់ច្រលំជាមួយនឹងសៀវភៅមុនៗដែលសរសេរឡើងមុនរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងទសវត្សរ៍៦០ ដែលសរសេរដោយដៃ ។ លោក ឆាំង យុ បានលើកឡើងថា លោកហៅ នួន ជា ថា «អ៊ុំ នួន» គ្រាន់តែបង្ហាញពីការគោរពទៅចាស់ទុំនៅក្នុងសង្គមកម្ពុជាប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តី លោក សុន អរុណ បន្តសួរពីសៀវភៅទាំងនេះដែលធ្វើឲ្យលោកប្រធាន និល ណុល កាត់និងរំឭកលោក អរុណ ថា វេលារបស់លោកជិតអស់ហើយ ។ លោកប្រធានស្នើថា លោក សុន អរុណ «គួរតែធ្វើកិច្ចការនេះនៅផ្ទះ» លើឯកសារដើម្បីផ្តោតលើសំណួររបស់លោកឲ្យបានប្រសើរជាងនេះ ។

ក្នុងការឆ្លើយតប លោក សុន អរុណ បានសួរទៅ លោក ឆាំង យុ ពី រូបថតនានាដែលបានពី របបនេះ ។ លោក ឆាំង យុ បានឆ្លើយថា មិនមែនរាល់រូបថតទាំងអស់នៅក្នុងរបបនេះត្រូវបានរកឃើញនៅក្នុងទួលស្លែងទេ ប៉ុន្តែថា រូបថតជាច្រើនត្រូវបានរកឃើញពីក្រៅប្រទេសរួមទាំងរូបថតខ្លះរកឃើញពីប្រទេសបារាំង ។ លោកបានពន្យល់ថា រូបថតជាច្រើននៅសម័យនោះត្រូវបានថតដោយសមាជិកប្រតិភូបរទេសជាមិត្តភាពដែលគាំទ្របក្សកុម្មុយនីស្តកម្ពុជា និងបានមកទស្សនានៅសម័យនោះ ។ លោកក៏បានផ្តល់សក្ខីកម្មផងដែរថា មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលកុនឯកសារជាច្រើនដែលថតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងបានធ្វើការថតចម្លងជាច្រើនច្បាប់ជូន អ.វ.ត.ក តែត្រូវធ្វើការរក្សាកម្មសិទ្ធិដែលបានផ្តល់មកមជ្ឈមណ្ឌលឯកសារកម្ពុជាដោយអ្នកផលិតភាពយន្ត ។

លោក សុន អរុណ បានសួរអំពីការស្នើបាត់ឯកសារនានាពីគុកក្រាំងតាចាន់ ។[៧] លោក ឆាំង យុ ឆ្លើយតបថា វាមិនត្រឹមត្រូវទេសម្រាប់មនុស្សដែលសន្និដ្ឋានទូលស្វែងគឺជាគុកតែមួយគត់ដែលរក្សាទុកឯកសារ និងចម្លើយសារភាពនោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ ។ លោក បានលើកឡើងថា លោកបានដឹងថាឯកសារទាំងនេះដែលអាចនៅសេសសល់ក្រោយពីរបបនេះនៅគុកក្រាំងតាចាន់ក្នុងសៀវភៅដែលសរសេរឡើងដោយ លោក ប៊េន គៀរនិន ប៉ុន្តែលើកឡើងថា គ្មានឯកសារនៅសេសសល់ទេនៅពេលដែលលោកទៅកាន់គុកនោះដើម្បីរកមើលឯកសារទាំងនេះ ។

បន្ទាប់មក លោក ឆាំង យុ ត្រូវបានសួរបន្ថែមទៀត ថាតើវាអាចទាញការសន្និដ្ឋានបានទេថាអ្នកជំនាញការវៀតណាមបានបន្លំកែប្រែឯកសារដែលបានធ្វើឡើងដោយបក្សកុម្មុយនីសកម្ពុជា ។ លោក ឆាំង យុ ឆ្លើយថា វាប្រហែលជាពិបាកណាស់សម្រាប់បុគ្គលវៀតណាម ក្នុងការកែប្រែ ឬបន្លំឯកសារដែលធ្វើឡើងដោយបក្សកុម្មុយនីសកម្ពុជានោះ ។ លោកពន្យល់ថា លោកមានការឆ្ងល់ណាស់ថា ជនជាតិវៀតណាមដែលនិយាយភាសាវៀតណាម អាចក្លែងបន្លំឯកសារនានា សរសេរជាភាសាខ្មែរ ជាពិសេសទៀតសម្រាប់អ្នកដែលប្រើពាក្យបច្ចេកទេស ដូចជា "សម្ភារនិយម" ដែលមិនដែលយល់ជាទូទៅនៅក្នុងប្រទេសកម្ពុជា ទោះបីជាប្រជាជនខ្មែរក៏ដោយនោះ ។

នេះជាការសួរសរុប ការសាកសួរ លោក ឆាំង យុ ដោយមេធាវីការពារក្តី នួន ជា និងការបញ្ចប់ការផ្តល់សក្ខីកម្មរបស់លោកផងដែរ លើនីតិវិធីនិងដំណើរការទាក់ទងទៅនឹងការប្រមូលឯកសារដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ លោកប្រធាន និល ណុន បានថ្លែងអំណរគុណដល់លោក ឆាំង យុ ដែលបានចំណាយវេលាផ្តល់សក្ខីកម្ម និងប្រកាសការឈប់សម្រាកសម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្ត សវនាការលើកស្តុតាងបន្តទៀតនៅថ្ងៃអង្គារ ទី៨ ខែកុម្ភៈ ឆ្នាំ២០១២ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាឯកសារកម្ពុជា គឺជាអ្នកឧបត្ថម្ភការឃ្លាំមើលសាលាក្តីកម្ពុជា និងលោក ឆាំង យុ ជានាយកនៃមជ្ឈមណ្ឌលនេះជាអ្នកកែសម្រួល ។

**-ចប់-**

[៧] គុកក្រាំង តាចាន់ មានទីតាំងនៅនីរតី ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ត្រូវបានជឿថាឋិត ក្រោមការគ្រប់គ្រងរបស់ តាម៉ុក ជាបុគ្គលសំខាន់មួយរបស់ខ្មែរក្រហមដែលបានស្លាប់នៅក្នុងឆ្នាំ២០០៦ នៅក្នុងមន្ទីរឃុំឃាំងរបស់រដ្ឋាភិបាលកម្ពុជា ។